# មេរៀនទី ១៥៤: នេហេមាកសាងកំផែងឡើងវិញ

## នេហេមា ២:១១-៦:១៩

**គោលបំណង៖** ព្រះជួយយើងបំពេញព័ន្ធកិច្ចសំរាប់ថ្វាយទ្រង់។

**ខគម្ពីរចងចាំ៖ ១ យ៉ូហាន ៤:៤** *“ពួកកូនតូចៗអើយអ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នានោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកីយ៍ផង។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ យើងទទួលយកនូវឧបសគ្គដើម្បីនាំយកនូវព្រះបន្ទូលរបស់ព្រះទៅកាន់ពិភព-លោកបាក់បែកមួយនេះ។ ក្នុងនាមយើងជាគ្រូបង្រៀន យើងត្រូវជួយកុមារឲ្យយល់ ហើយអនុវត្តតាមព្រះបន្ទូល និងកិច្ចការរបស់ព្រះយេស៊ូវ។ ពេលខ្លះយើងសួរខ្លួនឯងថាតើយើងមានចំណេះជំនាញ និងបេះដូងដើម្បីធ្វើការកិច្ចការទាំងអស់នេះឬអត់! សូមអាន **នេហេមា៤:៦** ហើយអធិស្ឋាន “ព្រះជាម្ចាស់ទូលបង្គំសូមថ្វាយដួងចិត្តរបស់កូនទាំងមូល និងអំណោយទានល្អៗ ព្រមទាំងកម្លាំងរបស់កូនទាំងអស់ ដើម្បីជួយកសាងអាណាចក្រថ្វាយទ្រង់នៅលើផែនដីនេះ។ អរព្រះគុណព្រះដែលបានដឹកនាំផ្លូវកូន និងជួយឲ្យកូនលូតលាស់ក្លាយជាគ្រូដែលមានទំនុកចិត្ត និងជាគ្រូដែលមានប្រសិទ្ធភាព។”

**ចំរៀង៖** ១. គឺជាការល្អ ២. គឺជាការល្អដែលសរសើរព្រះ ៣.ចូរមានកម្លាំងនិងមានចិត្តក្លាហានចុះ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «គប់បាល់អោយដួលដបទឹក»

**សម្ភារៈដែលត្រូវការ៖** ដបទឹក៧ និងកូនបាល់តូចៗមួយចំនួន




១. ចែកកុមារជាពីរក្រុម ហើយឲ្យពួកគេឈរជាជួរ។

២. គ្រូត្រូវដាក់ដបទឹកជាជួរនៅលើឥដ្ឋ (១០សង់ទីម៉ែត្រពីគ្នា។)

៣. ឲ្យតំណាងក្រុមទាំងពីរប៉ោវក្រុមដែលឈ្នះត្រូវឈរនៅចម្ងាយ ៥ ម៉ែត្រពីដបទឹក។ ក្រុមដែលឈ្នះត្រូវមានបាល់ម្នាក់មួយ ហើយចាប់ផ្ដើមគប់ដបទឹកនោះឲ្យដួល។ កុមារម្នាក់ៗមានឱកាសតែម្ដងប៉ុណ្ណោះក្នុងការលេងល្បែងនេះ គ្រូត្រូវរាប់ចំនួនដបដែលដួល។





៤. នៅពេលដែលក្រុមមួយលេងរួច ក្រុមមួយទៀតត្រូវលេងម្ដង។

៥. ក្រុមណាដែលគប់ដបទឹកឲ្យដួលបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដបទឹកប្រៀបបានទៅនឹងកំផែងទីក្រុងយេរូសាឡិម ដែលត្រូវបានផ្ដួលដោយសត្រូវអើចឹង។ ថ្ងៃនេះយើងនឹងរៀនពីរបៀបដែលកំផែងបានសាងសង់ឡើងវិញ។

### ៤. ការណែនាំមេរៀន

បើសិនជានរណាម្នាក់ឲ្យអ្នកសាងសង់ផ្ទះមួយ តើអ្នកអាចនឹងសាងសង់វាបានទេ? អ្នកដឹងថា នេះមិនមែនជារឿងងាយស្រួលនោះឡើយ ហើយវាស្ទើរតែមិនអាចទៅរួចទេសំរាប់ក្មេងៗក្នុងការធ្វើការងារនេះ។ ប៉ុន្តែប្រសិនបើព្រះជួយអ្នកវិញ? តើអ្នកនឹងអាចធ្វើវាបានទេ? ថ្ងៃនេះ យើងនឹងរៀនពីរាស្រ្តរបស់ព្រះអាចបំពេញកាតព្វកិច្ច ដែលមើលទៅហាក់បីដូចជាមិនអាចធ្វើបាន តែដោយសារតែព្រះបានជួយពួកគេនោះគេអាចធ្វើបាន។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជនជាតិយូដាជារាស្រ្តរបស់ព្រះតែងតែបានទទួលការបង្រៀនឲ្យស្រឡាញ់ និងទុកចិត្តព្រះ។ ប៉ុន្តែពួកគេមិនបានស្តាប់បង្គាប់ព្រះ ហើយថ្វាយបង្គំព្រះក្លែងក្លាយ និងរូបព្រះ។ ព្រះបានព្រមានពួកគេដើម្បីមិនឲ្យធ្វើបាបទៀត ហើយឲ្យគេងាកបែរទៅរកព្រះវិញ ប៉ុន្តែពួកគេមិនស្តាប់បង្គាប់ទេ។ ដូច្នេះព្រះបានអនុញ្ញាតឲ្យសាសន៍ដទៃចាប់ពួកគេជាឈ្លើយទៅឆ្ងាយពីប្រទេសរបស់ពួកគេគឺ បាប៊ីឡូន។ ទីក្រុងយេរូសាឡិមរបស់ពួកគេត្រូវបានដុតកម្ទេចចោល។

ក្រោយមកទៀត ពេលដែលជនជាតិយូដានៅជាឈ្លើយនៅបាប៊ីឡូន មានបុរសម្នាក់ឈ្មោះនេហេមា ចង់ត្រឡប់ទៅយេរូសាឡិមវិញ ដើម្បីសាងសង់ និងជួសជុលកំផែងឡើងវិញ វាគឺជាកំផែងការពារនៅជុំវិញទីក្រុងយេរូសាឡិម។ កំផែងមានសារៈសំខាន់ណាស់ ពីព្រោះវាជួយការពារកុំឲ្យសត្រូវចូលមកឈ្លានពាន ហើយការពារប្រជាជននៅក្នុងទីក្រុងឲ្យមានសុវត្ថិភាព។ ការកសាងកំផែងនៅជុំវិញទីក្រុងទាំងមូលគឺជាការងារធំ ជាការងារដែលមិនអាចទៅរួច ហើយនេហេមាក៏បានដឹងផងដែរ។

នេហេមាបានមកទីក្រុងយេរូសាឡិម ហើយបានកើតទុក្ខក្រោយពីបានឃើញស្ថានភាពទីក្រុងយេរូសាឡិម ទីក្រុងដែលស្រស់ស្អាតរបស់គាត់ត្រូវបានបំផ្លាញ។ កំផែងត្រូវបានដុតកំទេចចោល ហើយបាក់បែកគ្រប់ទីកន្លែង។ វាមើលទៅហាក់ដូចជាមិនអាចទៅរួចទេដែលពួកគេអាចសាងសង់វាឡើងវិញបាន។ កំផែងដែលត្រូវការសាងសង់ឡើងវិញនៅជុំវិញទីក្រុងគឺចំងាយជាង ៤,០០០ម៉ែត្រ និងមានកំពស់១២ម៉ែត្រ។ ប៉ុន្តែនេហេមាបានអធិស្ឋាន ហើយប្រាប់ទៅជនជាតិអ៊ីស្រាអែលថា “ព្រះនៃស្ថានសួគ៌នឹងប្រទានឲ្យយើងបានជោគជ័យ។” ព្រះជួយយើងដើម្បីបំពេញព័ន្ធកិច្ចសំរាប់ថ្វាយទ្រង់។ អ្នកគ្រប់គ្នាត្រូវធ្វើការរួមគ្នាដើម្បីជួយសាងសង់កំផែងឡើងវិញ៖ ជាងមាស អ្នកផលិតទឹកអប់ អ្នកគ្រប់គ្រង បូជាចារ្យ ស្រ្តី និងកុមារទាំងអស់ បានរួបរួមគ្នាកសាងកំផែងក្រុងយេរូសាឡិមឡើងវិញ។

ពេលដែលកំផែងកំពុងសាងសង់ នេហេមាត្រូវបានមនុស្សតិះដៀល និងសើចចំអក ហើយគិតថាគាត់ល្ងង់ ដោយអ្នករស់នៅក្បែរនោះ។ ជីវិតរបស់នេហេមាត្រូវបានគំរាមកំហែង ហើយកម្មករក៏ត្រូវបានគំរាមកំហែងផងដែរ។ តើការគំរាមកំហែងទាំងនេះអាចបញ្ឈប់ពួកគេបានទេ? ទេ វាគ្រាន់តែបង្អង់គេបន្តិចតែប៉ុណ្ណោះ តែពួកគេមិនឈប់ទេ។ ពួកគេដឹងថាព្រះបានជួយដល់ពួកគេ។ តាមពិតទៅពួកគេបានសំរេចក្នុងការសាងសង់កំផែង ដែលខ្ពស់ហើយវែងក្នុងរយៈពេល៥២ថ្ងៃ! វាមិនអាចទៅរួចទេដែលមនុស្សអាចធ្វើការងារនេះដោយខ្លួនឯងបាន ប៉ុន្តែជាមួយនឹងជំនួយមកពីព្រះគ្រប់យ៉ាងអាចទៅរួច!

មានពេលជាច្រើនដែលយើងធ្វើការថ្វាយព្រះ ហើយមានបញ្ហាជាច្រើនតាមមកជាមួយដូចដែលនេហេមាជួបអញ្ចឹងដែរ។ ដោយព្រោះតែសត្រូវរបស់ព្រះគឺវិញ្ញាណអាក្រក់មិនចង់ឲ្យយើងធ្វើការថ្វាយព្រះទេ។ ប៉ុន្តែកុំបារម្ភឡើយ ពីព្រោះព្រះសន្យាថានឹងជួយយើងជានិច្ច! កំផែងបានសាងសង់ចប់ដែលពីមុនមនុស្សគ្រប់គ្នាមិនជឿថាវា

អាចទៅរួច! សូម្បីតែសត្រូវរបស់នេហេមាក៏បានដឹងថា ការនេះអាចសំរេចបានដោយសារតែព្រះប៉ុណ្ណោះ។ នេះគឺជាអ្វីដែលបានកើតឡើងពេលដែលព្រះជួយដល់ពួកយើង។

### ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាព្រះអនុញ្ញាត្តឲ្យជនជាតិយូដាក្លាយជាឈ្លើយសឹករបស់បាប៊ីឡូន?
*ពីព្រោះពួកគេមិនស្តាប់បង្គាប់ព្រះ និងថ្វាយបង្គំរូបព្រះក្លែងក្លាយ*

២. តើនរណាធ្វើដំណើរទៅទីក្រុងយេរូសាឡិមដើម្បីសាងសង់កំផែងទីក្រុងឡើងវិញ? *លោកនេហេមា*

៣. តើកំផែងមានប្រវែង និងកំពស់ប៉ុន្មាននៅជុំវិញទីក្រុងយេរូសាឡិម?
*ប្រហែលប្រវែង ៤០០០ ម៉ែត្រ កំពស់ ១២ ម៉ែត្រ*

៤. តើគេប្រើពេលប៉ុន្មានដើម្បីសាងសង់កំផែងនៅជុំវិញទីក្រុងយេរូសាឡិមឲ្យហើយ? *៥២ថ្ងៃ*

៥. តើការជួយអ្វីខ្លះដែលអ្នកត្រូវការពីព្រះ? *សូមឲ្យកុមារឆ្លើយ*

### ៧. ល្បែងកំសាន្ត «សាងសង់កំផែងកែវក្រដាស»



**សម្ភារៈដែលត្រូវការ៖** កែវក្រដាស និងតុ

១. បែងចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជា២ជួរ។

២. ចែកកែវក្រដាសឲ្យកុមារម្នាក់១។

៣. នៅពេលដែលល្បែងចាប់ផ្តើមលេង ពួកគេត្រូវព្យាយាមរៀបកែវក្រដាសបញ្ឈរជាជង់ឲ្យបានកាន់តែខ្ពស់តាមតែពួកគេអាចធ្វើបាន។ ប្រសិនបើជាជង់កែវក្រដាសរបស់ពួកគេដួល ប្រាប់កុមារកុំឲ្យគិតពីពែងក្រដាសរបស់អ្នកផ្សេង ហើយបន្តរៀបតែកែវក្រដាសរបស់ពួកគេឡើងវិញតែប៉ុណ្ណោះ។

៤. ក្រុមណាដែលរៀបកែវក្រដាសបានខ្ពស់ជាងគេនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់ទៅកុមារថា ការដែលយើងសាងសង់កំផែងដោយប្រើកែវក្រដាសគឺពិបាកណាស់។ ប៉ុន្តែរាស្ត្ររបស់ព្រះអាចសាងសង់កំផែងដែលមានប្រវែងវែង និងកំពស់ខ្ពស់នៅជុំវិញទីក្រុងយេរូសាឡិមទាំងមូលបាន។ អ្វីដែលមើលទៅមិនអាចទៅរួចជាមួយនឹងមនុស្ស វានឹងក្លាយទៅជាងាយស្រួលខ្លាំងនៅពេលដែលព្រះជួយយើង!

### ៨. ខគម្ពីរចងចាំ ១ យ៉ូហាន ៤:៤

### ៩. ហត្ថកម្ម «នេហេមាសាងសង់កំផែងឡើងវិញ»



**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ កាវបិត

១. បោះពុម្ពក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេផាត់ពណ៌រូបភាពក្នុងក្រដាសហត្ថកម្ម។

២. កាត់រូបជញ្ជាំងថ្មទាំង២ ហើយបិតនៅលើរូបបុរស២នាក់នោះ។

៣. កាត់គំនូសដាច់ៗនៃជញ្ជាំងនោះ ហើយបត់វាជាពីរដើម្បីឲ្យវាអាចឈរបាន។
៤. ពន្យល់កុមារថា ទោះបីវាមិនមែនជាកាតព្វកិច្ចងាយស្រួលសំរាប់នេហេមា និងជនជាតិយូដា ដើម្បីសាងសង់កំផែងនេះឡើងវិញ តែពួកគេនៅតែអាចធ្វើបានជាមួយនឹងការជួយរបស់ព្រះ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# នេហេមាសាងសង់កំផែងឡើងវិញ





សំភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម កូលែ កន្ត្រៃ ការបិត

១. បោះពុម្ពក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេផាត់ ពណ៌រូបភាពក្នុងក្រដាសហត្ថកម្ម។

២. កាត់រូបជញ្ជាំងថ្មទាំង២ ហើយបិតនៅលើរូបបុរស២នាក់នោះ។

៣. កាត់គំនូសដាច់ៗនៃជញ្ជាំងនោះ ហើយបត់វាជាពីរដើម្បីឲ្យវាអាច ឈរបាន។

៤. ពន្យល់កុមារថា ទោះបីវាមិនមែនជាកាតព្វកិច្ចងាយស្រួលសំរាប់ នេហេមា ហើយនិងជនជាតិយូដា ដើម្បីសាងសង់កំផែងនេះឡើងវិញ តែពួកគេនៅតែអាចធ្វើបានជាមួយនឹងការជួយរបស់ព្រះ។

